*បានចេញជាផ្លូវការ*

# សេចក្តីថ្លែងការណ៍រួម

## គុណភាពសំណង់ និង សុវត្ថិភាពកម្មករសំណង់នៅកម្ពុជាត្រូវតែមានការធានា

ភ្នំពេញ. ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០១៩



*ក្រុមជួយសង្គ្រោះចម្រុះលើកសាកសពកម្មករសំណង់ចេញពីគំនរអគារបាក់រលំ*

យើងខ្ញុំជាតំណាងសហពន្ធ័សហជីព សមាគម សហគមន៍ អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ រួមទាំងអ្នកការពារ សិទ្ធិមនុស្ស ដែលធ្វើការលើវិស័យ សិទ្ធិការងារ និងសិទ្ធិមនុស្ស មានសេចក្តីសោកស្តាយ និងរន្ធត់ជា ពន់ពេកចំពោះហេតុការណ៍បាក់អគារកំពុងសាងសង់កំពស់៧ជាន់ ស្ថិតនៅភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមិថុនាឆ្នាំ២០១៩ វេលាម៉ោងប្រមាណ៤ទៀបភ្លឺ។ ជាមួយគ្នានេះយើងខ្ញុំសូមសម្តែងនូវសេចក្តីកោតសរសើរ ចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមសង្គ្រោះចម្រុះ ដែលខិតខំបំពេញការងាររុករកជនរងគ្រោះដោយស្មារតីមនុស្សធម៌ និងអស់ពីលទ្ធភាពរបស់ខ្លួនក្នុងការរុករក ជនរងគ្រោះអស់រយៈពេលជាង ៦០ម៉ោងកន្លងទៅ ។

គិតមកដល់រសៀលថ្ងៃទី២៤ខែមិថុនាឆ្នាំ២០១៩ កម្មករសំណង់ប្រុសស្រីចំនួន៥៤នាក់ ក្នុងនោះបាត់បង់ជីវិតចំនួន២៨នាក់មានស្ត្រី៥នាក់ និងអ្នករបួសចំនួន២៦នាក់ផ្សេងទៀត ត្រូវបាន ក្រុមជួយសង្គ្រោះចម្រុះរុករកឃើញនិងសង្គ្រោះបានទាន់ពេលវេលា។ ក្នុងចំណោមអ្នករងរបួស ទាំងនោះយ៉ាងហោចណាស់មានកម្មករកម្មការនីអាយុ១៦ឆ្នាំពីរនាក់ និងស្ត្រីម្នាក់ផ្សេងទៀត អ្នករងរបួសភាគច្រើនកំពុងសំរាកព្យាបាលនៅមន្ទីពេទ្យបង្អែកខេត្តព្រះសីហនុ។ ជនរងគ្រោះ ទាំងនោះ សុទ្ធសឹងជាកម្មករសំណង់ជនជាតិខ្មែរចំណាកស្រុកមកពីខេត្ត/ក្រុងផ្សេងៗគ្នាក្នុង ប្រទេសកម្ពុជា ។

នៅព្រលប់មុនថ្ងៃកើតហេតុ សាក្សីឃើញផ្ទាល់ភ្នែកបានឲ្យដឹងថាមានរថយន្តដឹកកម្មករ ខ្មែរ ប្រុសស្រីចំនួនពីរគ្រឿងដែលមានមនុស្សប្រមាណ ៣០ ទៅ ៤០នាក់ដឹកចូលក្នុងការដ្ឋាន ហើយស្នាក់នៅ

ទីនោះ។ គេក៏បានដឹងដែរថានៅជាន់ផ្ទាល់ដីនៃអគារបាក់ស្រុតមានគ្រួសារកម្មករ និងស្ត្រីដែលជាភរិយាបានស្នាក់ក្នុងអាគារនេះផងដែរ ។

សំណង់នេះត្រូវបានមៅការសាងសង់ដោយក្រុមហ៊ុនសំណង់ចិនឈ្មោះ XI GANG TANG GONG GOU JI HAISAO ដែលត្រូវបានគេដឹងជាសាធារណៈថា ក្រុមហ៊ុននេះគ្មានច្បាប់អនុញ្ញាត ឲ្យធ្វើសកម្មភាពសាងសង់ពីអាជ្ញាធរមានសមត្ថកិច្ចឡើយ។ ការដ្ឋានសំណង់ត្រូវបានធ្វើឡើង នៅលើផ្ទៃដីទំហំ១៥ម៉ែត្រ និង៣០ម៉ែត្រកំពស់៧ជាន់ ស្ថិតនៅទីប្រជុំជនខេត្តព្រះសីហនុ ដោយសាងសង់បានសម្រេចជាង៨០% នៃគំរោង ទោះបីជាសមត្ថកិច្ចដែនដីធ្វើការហាមឃាត់ចំនួនពីរដងរួចមកហើយក៏ដោយ។

កាលពីខែតុលា ឆ្នាំ២០១៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រកឃើញថា មានការដ្ឋានសំណង់ជាច្រើនក្នុងខេត្តព្រះសីហនុ ជាសំណង់ពុំមានលិខិតអនុញ្ញាតសាងសង់ ជាហេតុបណ្តាលឱ្យកើតមានដំណង់ខុសបច្ចេកទេស ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព និងគុណភាពសំណង់ ។

*លោក **សុខ គីន** ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) មានប្រសាសន៍ថា៖"ការអភិវឌ្ឍន៍ទីក្រុង ត្រូវតែគិតដល់បរិដ្ឋាន សុខមាលភាព និងសុវត្ថិភាព សារធារណៈ ដែលទាំងនេះជាតួនាទីរបស់រដ្ឋ។ ការបំពានលើបំបម្រាម ឬសេចក្តីណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចគឺជាការល្មើសច្បាប់ ដែលត្រូវតែផ្តន្ទាទោសយ៉ាងតឹងរឹង អ្នកសមគំនិត និងអ្នកប្រព្រឹត្តត្រូវទទួលទោសដូចគ្នា"។*

កម្មករមួយក្រុមបានឲ្យដឹងថា ក្រុមហ៊ុននេះខ្ជីខ្ជាក្នុងការអនុវត្តន៍នូវនិយាមសុវត្ថិភាព និងសុខភាព។ យ៉ាងហោចណាស់ជនរងគ្រោះជិត៦០នាក់ជាមួយនឹងក្រុមគ្រួសារ ដែលជាកម្មករបានយកអគារដែលកំពុងសាងសង់ធ្វើជាកន្លែងស្នាក់អាស្រ័យនៅប្រចាំថ្ងៃផង និងសាងសង់ផង ជាក់ស្តែងនៅម៉ោងកើតហេតុគឺជាម៉ោងដែលកម្មករទាំងនោះកំពុងសម្រាក់នៅឡើយ ។

ក្រោយថ្ងៃកើតហេតុមួយថ្ងៃ រដ្ឋាភិបាលបានបង្កើតនូវគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់ខេត្តព្រះសីហនុ ដែលមានគោលបំណងក្នុងការត្រួតពិនិត្យបទដ្ឋានបច្ចេកទេស បទដ្ឋានគតិយុត្ត ស្តង់ដារសំណង់ ស្តង់ដារសុវត្ថិភាព និងគុណភាពសំណង់នៅតាមការដ្ឋានសំណង់នៅខេត្តព្រះសីហនុ ដើម្បីបង្ការ និងទប់ស្កាត់នូវគ្រោះមហន្តរាយបែបនេះទៀត ។

*លោក **យុន ថារ៉ូ** អ្នកគ្រប់គ្រងកម្មវិធីការងារនៃអង្គការមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) មានប្រសាសន៍ថា៖ [ការអនុវត្តន៍បទដ្ឋានសុវត្ថិភាពនៅតាមការដ្ឋានសំណង់នីមួយៗត្រូវតែធានាឲ្យមានប្រសិទ្ធភាព ការយកទីតាំងការដ្ឋានសំណង់ធ្វើជាកន្លែងស្នាក់នៅផងនិងសាងសង់ផងគឺជាហានិភ័យសម្រាប់ជីវិតមនុស្សជាពិសេសកម្មករសំណង់ និងក្រុមគ្រួសាររបស់គាត់។ អ្នកទទួលខុសត្រូវសាងសង់ និងម្ចាស់សំណង់មិនត្រូវឲ្យរួចផុតពីបទ ព្រហ្មទណ្ឌដោយគ្រាន់តែចេញសំណងដល់ជនរងគ្រោះនោះឡើយ]។*

ហេតុការណ៍បាក់រលំអគារនៅពេលកំពុងសាងសង់បែបនេះ មិនមែនជាលើកទីមួយឡើយនៅកម្ពុជា។ កាលពីពាក់កណ្តាលឆ្នាំ២០១៨ ក៏មានករណីបាក់ប្លង់សេជាន់ទី២៣ នៃខុនដូ Mekong View៦

ដែលបណ្តាលអោយមនុស្សយ៉ាងហោចណាស់៥នាក់រងរបួសនិងបាត់ខ្លួន២នាក់។ កាលពីពាក់កណ្តាលខែ សីហា ឆ្នាំ២០១៨ ក៏មានករណីបាក់រលំអគារ មានទីតាំងស្ថិតនៅក្នុងខណ្ឌ ឫស្សីកែវ ខណៈពេលដែលកម្មករកំពុងបម្រើការងារក្នុងពេលដែលឡានដឹកប៉េតុងបាញ់ប៉េតុងចាក់ពិដាននៅអគារជាន់ទីមួយ ហើយចៃដន្យមិនមានអ្នករងគ្រោះថ្នាក់នោះទេ។ នៅក្នុងខែមេសា ឆ្នាំ២០១៣ ក៏មានករណីបាក់ពិដាននៅរោងចក្រផលិតស្បែកជើង Wing Star Shoes ស្ថិតក្នុងខេត្ត កំពង់ស្ពឺ និងបានសម្លាប់កម្មការនីអាយុ១៥ឆ្នាំម្នាក់ និងកម្មករអាយុ ២៥ឆ្នាំ ម្នាក់។ នៅក្នុងខែមេសា ឆ្នាំ២០១៦ ក៏មានករណីការបាក់រលំស្ពាននៅក្នុងរោងចក្រ Top World Garment.

ជារឿយៗក្នុងគម្រោងសំណង់នីមួយៗ មានក្រុមហ៊ុនម៉ៅការបន្តជាច្រើន ដែលប្រើកម្លាំងពលកម្មប្រុស ស្រី ដោយគ្មានការផ្តល់លក្ខខណ្ឌការងារសមរម្យ បំពានសិទ្ធិជាមូលដ្ឋានរបស់កម្មករដែលបានកំណត់ក្នុងច្បាប់ស្តីពីការងារ និងមិនបំពេញកាតព្វកិច្ចធានាខាងសុវត្ថិភាព សុខភាពដល់កម្មករឡើយ ។

ដោយមើលឃើញនូវហេតុការណ៍ដ៏រន្ធត់នេះហើយដើម្បីចូលរួមជាដំណោះស្រាយ និងបង្ការសុវត្ថិភាពដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងនាមតំណាង សហពន្ធ័ សហជីព សមាគម និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលធ្វើការលើវិស័យសិទ្ធិការងារ សិទ្ធិមនុស្ស សូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាល និងអ្នកពាក់ពន្ធ័អភិវឌ្ឍន៍វិស័យឯកជន មានវិធានការដូចខាងក្រោមៈ

១. ផ្អាកជាបន្ទាន់នូវគម្រោងសាងសង់ទាំងអស់នៅខេត្តព្រះសីហនុ រង់ចាំឱ្យមានការត្រួត ពិនិត្យវាយតម្លៃពីស្ថាប័នជំនាញ ដើម្បីឲ្យប្រាកដថាគម្រោងសាងសង់នីមួយៗមានច្បាប់អនុញ្ញាត និងមានគុណភាពតាមស្តង់ដាសុវត្ថិភាព។ វិធានការនេះកត្រូវតែអនុវត្តន៍ផងដែរចំពោះសំណង់នានាក្នុងព្រះរាជាណាចក្រកម្ពុជាដែលសង្ស័យថាមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ និងធ្វើការសាងសង់តាមបទដ្ឋានសុវត្ថិភាពសំណង់ត្រឹមត្រូវ ។

២. ជម្រុញអោយមានការចុះធ្វើអធិការកិច្ចការងារជាប្រចាំអោយមានប្រសិទ្ធិភាព និងតម្លាភាព ដើម្បីពិនិត្យមើលអំពីលក្ខខណ្ឌសុវត្ថិភាពនិងបទដ្ឋានការងាររបស់កម្មករសំណង់នៅទូទាំងប្រទេសកម្ពុជា។

៣. សូមផ្តល់សំណងការខូចខាតដល់អ្នករងគ្រោះ អោយបានសមរម្យរួមទាំងអ្នករស់ក្នុងបន្ទុកគ្រួសារជនរងគ្រោះ ។

៤. ស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អ្នកសមគំនិតត្រូវទទួលទោសដូចអ្នកប្រព្រឹត្តផ្ទាល់ដែរ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែទទួលខុសត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ ទទួលទោសដូចអ្នកប្រព្រឹត្តផ្ទាល់ដែរ។

៥. បញ្ឈប់ជាបន្ទាន់នូវសកម្មភាពម៉ៅការបន្តដែលគ្មានអាជ្ញាប័ណ្ណ និងធានាការអនុវត្តន៍បទដ្ឋាននិយាមសុវត្ថិភាពគ្រប់ការដ្ឋានសំណង់។

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

១. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក- ADHOC) (កម្ពុជា)
២.សមាគមធាងត្នោត (STT) (កម្ពុជា)
៣.សមាគមបណ្តាញយុវជនកម្ពុជា (CYN) (កម្ពុជា)
៤.សម្ព័ន្ធសហជីពកម្ពុជា (CATU) (កម្ពុជា)
៥.សហព័ន្ធសហជីពឯករាជ្យ (NTUFEE) (កម្ពុជា)
៦.គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌ នៅកម្ពុជា (ខុមហ្វ្រែល) (កម្ពុជា)
៧.សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) (កម្ពុជា)
៨.សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) (កម្ពុជា)
៩.សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) (កម្ពុជា)
១០.សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) កម្ពុជា
១១.សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF) (កម្ពុជា)
១២.មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) (កម្ពុជា)
១៣.សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ (NIFTUC) (កម្ពុជា)
១៤.សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករនៃក្រុមហ៊ុនណាហ្គាវើលដ៏ (L.R.S.U) (កម្ពុជា)
១៥.អង្គការ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (សង់ត្រាល់) (កម្ពុជា)
១៦.សម្ព័ន្ធសហជីពកម្មករដើម្បីការងារ (UCL) (កម្ពុជា)
១៧.សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC) (កម្ពុជា)
១៨.សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) (កម្ពុជា)
១៩. អង្គការការពារសិទ្ធិជនជាតិភាគតិច (MIRO) (កម្ពុជា)
២០.អង្គការ អាក់សិនអេដ (ActionAid) (កម្ពុជា)
២១.អង្គការ ក្លាហាន (Klahaan Organization) (កម្ពុជា)
២២.មជ្ឈមណ្ឌលសាមគ្គីភាពការងារ (SC/ACILS) (កម្ពុជា)
២៣.សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើអន្តរជាតិ (BWI) (អាស៊ីប៉ាស៊ីភិច)
២៤.សហព័ន្ធសហជីពវិស័យសាធារណៈអន្តរជាតិ (PSI) (អន្តរជាតិ)
២៥.អង្គការ (NaZemi, Czech Republic) (សាធារណៈរដ្ឋឆែក)
២៦.អង្គការ សូលីដា (Solidar Suisse) (ស្វីស)
២៧.កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) (កម្ពុជា)

២៨.អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) (កម្ពុជា)
២៩.សហភាពការងារកម្ពុជា (CLC) (កម្ពុជា)
៣០.មជ្ឈមណ្ឌលធនធានតាមដានត្រួតពិនិត្យអាស៊ី (AMRC) (ហុងកុង)

៣១.អង្គការ Globalization Monitor (ហុងកុង)

៣២. Borderless Movement (ហុងកុង)

៣៣. Labour Education and Service Network (ហុងកុង)

៣៤. Yokohama Action Research (ជប៉ុន)

៣៥. China Labour Bulletin, Hong Kong (ហុងកុង)

៣៦. JTNC Watch (ជប៉ុន)

៣៧. China Labour Bulletin (ហុងកុង)

៣៨. Maquila Solidarity Network (MSN) (កាណាដា)

៤៩. Civil Rights Defenders (CRD) (ស៊ុយអែត)

៤០. Future In Our Hands (FIOH) (ណ័រវែស)

៤១. Local Initiative for OHS Network (ឥណ្ឌូនេស៊ី)

៤២. Asia Floor Wage Alliance (AFWA) (អាស៊ី)

៤៣. Sedane Labour Centre LIPS (ឥណ្ឌូនេស៊ី)

៤៤. Serikat Pekerja Nasional (SPN) ឥណ្ឌូនេស៊ី

៤៥. Serikat Buruh Indonesia (GSBI) ឥណ្ឌូនេស៊ី

៤៦. Federasi Buruh Lintas Pabrik (FBLP) ឥណ្ឌូនេស៊ី

៤៧. Konfederasi Aliansi Serikat Buruh (KASBI) ឥណ្ឌូនេស៊ី

៤៨. Trade Union Rights Center (TURC) ឥណ្ឌូនេស៊ី

៤៩. Social Action for Community and Development (SACD) ឥណ្ឌូនេស៊ី

៥០. Korean House for International Solidarity (កូរ៉េ)

៥១. Clean Clothes Campaign (South East Asia) (អាស៊ីខាងត្បូង)

៥២. Clean Clothes Campaign (East Asia) (អាស៊ីអាគ្នេយ៍)

៥៣. Norwegian People's Aid (NPA) (ណ័រវែស)

៥៤. MAP Foundation (ថៃ)

៥៥. Workers Assistance Center, Inc. (ហ្វីលីពីន)

៥៦. FOCUS on Global South (ថៃ)

៥៧. Fair Action (ស៊ុយអែត)

៥៨. Garment and Allied Workers Union-North India (ឥណ្ឌា)

៥៩. National Free Trade Union, Sri Langka (ស្រីលង្កា)

៦០. Dabindu Collective, Sri Langka (ស្រីលង្កា)

៦១. TWFI (HMS) (ឥណ្ឌា)

៦២. Garment Labour Union (GLU) (ស្រីលង្កា)

៦៣. Free Trade Zones & General Services Employees Union (FTZ&GSEU) (ស្រីលង្កា)

៦៤. Workers Empowerment (ហុងកុង)

៦៥. អង្គការសមធម៌កម្ពុជា (EC) (កម្ពុជា)

៦៦. Magnus Kjellson, អ្នកតស៊ូមតិសិទ្ធិការងារ (ស៊ុយអែត)

៦៧. Karins Ström, អ្នកតស៊ូមតិសិទ្ធិការងារ (ស៊ុយអែត)

៦៨. Pheareak Ly, អ្នកតស៊ូមតិសិទ្ធិការងារ (កម្ពុជា)

៦៩. Pech Polet, អ្នកតស៊ូមតិសិទ្ធិមនុស្ស (កម្ពុជា)

៧០. Sen Chanthou, អ្នកតស៊ូមតិសិទ្ធិមនុស្សក្រម (កម្ពុជា)

៧១ Chrek Sophea , អ្នកតស៊ូមតិសិទ្ធិមនុស្ស (កម្ពុជា)

៧២. Chroeung Saphoeurt, អ្នកតស៊ូមតិសិទ្ធិមនុស្ស (កម្ពុជា)

៧៣. Rita Olivia Tambunan, អ្នកតស៊ូមតិសិទ្ធិមនុស្សឥណ្ឌូនេស៊ី (កម្ពុជា)

៧៤. សហគមន៍ដីធ្លីបឹងប្រាំ (កម្ពុជា)

៧៥. សហគមន៍ស្ដីក្រោមរហាលសូង (កម្ពុជា)

៧៦. សហគមន៍បុសស្នំ (កម្ពុជា)

៧៧. សហគមន៍អន្លង់រុន (កម្ពុជា)

៧៨. សហគមន៍អណ្ដូងកន្ទួត (កម្ពុជា)

៧៩.សហគមន៍ដីធ្លីភូមិក្ដីបថ្ម (កម្ពុជា)

៨០.សហគមន៍ដីធ្លីភូមិអូរស្វាយ (កម្ពុជា)

៨១. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (កម្ពុជា)

៨២. សហគមន៍ដីធ្លីភូមិស្នឹងបត់ (កម្ពុជា)

៨៣. សហគមន៍ដីធ្លីផ្លូវរថភ្លើងភូមិផ្សារកណ្ដាល (កម្ពុជា)

៨៤. សហគមន៍ដីធ្លីភូមិតាត្រៃ (កម្ពុជា)

៨៥. សហគមន៍ស្រែប្រាំង (កម្ពុជា)

៨៦. សហគមន៍ដីធ្លីជីខក្រោម (កម្ពុជា)

៨៧. សហគមន៍ដីធ្លីជីខលើ (កម្ពុជា)

៨៨. សហគមន៍នេសាទកោះស្រឡៅ (កម្ពុជា)

៨៩. សហគមន៍នេសាទសម្រស់កោះស្ដេច (កម្ពុជា)

៩០. សហគមន៍ដីធ្លីកោះស្ដេច (កម្ពុជា)

៩១. សហគមន៍ព្រៃឈើពេជ្រចង្វាល្អឆើត (កម្ពុជា)

៩២. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស(កម្ពុជា)

៩៣. សហគមន៍ព្រៃឈើដីធ្លីទួលសំរោង (កម្ពុជា)

៩៤. សហគមន៍ភ្នំនាងកង្រី (កម្ពុជា)

៩៥. សហគមន៍អភិរក្សអភិវឌ្ឍន៍ធនធានជលផល (កម្ពុជា)

៩៦. សហគមន៍នេសាទ (កម្ពុជា)

៩៧. សហគមន៍នេសាទព្រៃពាយ (កម្ពុជា)

៩៨. សហគមន៍ភ្នំត្នោត (កម្ពុជា)

៩៩. សហគមន៍កំពង់សាមគ្គី (កម្ពុជា)

១០០. សហគមន៍សាមគ្គីភ្នំជាំម្លូរ (កម្ពុជា)

១០១. សហគមន៍ត្រពាំងសង្កែ (កម្ពុជា)